**ច្បាប់ចម្លង**

# ព្រះរាជក្រម

នស/រកម/១២៩៦/៣១

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី


រដ្ឋសភា
ចូល លេខ ៧៣០
ថ្ងៃទី ៤ . ១ . ៩៧ ម៉ោង ១១.៣០
បញ្ជូនទៅ........................


* * * * * * * * *

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និង នាយករដ្ឋមន្ត្រីទី២
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស.៩៤ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ ១៩៩៤ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែតុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រីទាំងពីរ និង អំពីទេសរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អតិរេករដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## ប្រកាសឲ្យប្រើ

ច្បាប់ស្តីពី ការអនុម័តយល់ព្រមឲ្យព្រះរាជាណាចក្រកម្ពុជាចូលជាសមាជិកនៃសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃ ទី១៩ វិច្ឆិកា ឆ្នាំ១៩៩៦ នាសម័យប្រជុំលើកទី ៧ នីតិកាលទី១ ដែលមានសេចក្តីទាំងស្រុងដូចតទៅ :

ច្បាប់ចម្លង

# ច្បាប់

## ស្តីពី

## ការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជា
## ចូលជាសមាជិកនៃសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ

**ច្បាប់ចម្លង**

**មាត្រា ១.-**

អនុម័តយល់ព្រមលើកិច្ចព្រមព្រៀងនៃសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិដែលមានអត្ថបទភ្ជាប់មកជាមួយ និងយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាសមាជិកនៃសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិនេះ ។

**មាត្រា ២.-**

អនុម័តយល់ព្រមឱ្យរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាទិញភាគហ៊ុនរបស់សាជីវកម្មនេះជាទឹកប្រាក់ចំនួន បីរយសាមសិបប្រាំបួនពាន់ដុល្លារអាមេរិក (៣៣៩.០០០ USD) ។

**មាត្រា ៣.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាត្រូវបន្តនីតិវិធីទាំងឡាយដើម្បីបញ្ចូលព្រះរាជាណាចក្រកម្ពុជាជាសមាជិកនៃសាជីវកម្មនេះ ។

**មាត្រា ៤.-**

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

*ធ្វើនៅរាជធានីភ្នំពេញ , ថ្ងៃទី២០ខែ ធ្នូ ឆ្នាំ ១៩៩៦*

**ព្រះហស្ថលេខា**

**នរោត្តម សីហនុ**

**បានបង្គំទូលថ្វាយ និង ជំរាបជូន**
**សម្តេចនាយករដ្ឋមន្ត្រីទី១ និង ទី២**
**ទេសរដ្ឋមន្ត្រីទទួលបន្ទុកនីតិសម្បទា និង អភិវឌ្ឍន៍**
**និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**ហត្ថលេខា**

**គាត ឈន់**

**បានយកសេចក្តីក្រាបបង្គំទូលថ្វាយ**
**សូមឡាយព្រះហស្ថលេខាព្រះមហាក្សត្រ**

| **នាយករដ្ឋមន្ត្រីទី១** | **នាយករដ្ឋមន្ត្រីទី២** |
|---|---|
| **ព្រះហត្ថលេខា** | **ហត្ថលេខា** |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

លេខ : ៦៤៦ ច.ល.
ដើម្បីចំលងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ ១៩៩៦
អគ្គលេខាធិការរងរាជរដ្ឋាភិបាល